# បទពិសោធន៍ នៃការចិញ្ចឹមអន្ទង់ ក្នុងអាងប្លាស្ទិកជាលក្ខណៈគ្រួសារ

*រៀបរៀងដោយ : រដ្ឋបាលជលផល*

ប្រិយមិត្ត អ្នកអាន ជាទីមេត្រី! ពេលដែលលោក អ្នក បានចាប់យកសៀវភៅនេះ មកអាន យើងខ្ញុំយល់ថា លោកអ្នក ប្រហែលជាអ្នកដែលមិនខ្លាចត្រីអន្ទង់ទេ ហើយប្រហែលជាអ្នកដែលចូលចិត្តពិសារអន្ទង់ថែមទៀតផង ឬ យ៉ាងហោចណាស់ ក៏ជាអ្នកដែលមានបំណងចូលរួមក្នុងការពង្រីកសកម្មភាពអភិវឌ្ឍន៍ការចិញ្ចឹមអន្ទង់ ដល់បណ្តាកសិកររបស់យើងដែរ។ អន្ទង់ កំពុងមានតម្លៃសេដ្ឋកិច្ចខ្ពស់ ព្រោះទទួលការពេញនិយមក្នុងការបរិភោគ ដោយអ្នកប្រើប្រាស់ បានចាត់ទុកថា ជាធាតុផ្សំមុខម្ហូបប៉ូវកម្លាំង។ កន្លងមក យើងសង្កេតឃើញមានចលនាចិញ្ចឹមអន្ទង់ដែរ ដើម្បីរួមចំណែក ផ្គត់ផ្គង់តម្រូវការលើទីផ្សារ ប៉ុន្តែកសិករមួយចំនួន ទទួលបានជោគជ័យ និងកសិករមួយចំនួនទទួលបានត្រឹមតែបទពិសោធន៍ ។ អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំ បានរួមគ្នាប្រមូលព័ត៌មាន ពីកសិករឈ្មោះ **ខឹម សារិទ្ធ** ដែលបានឆ្លងកាត់បទពិសោធន៍ចិញ្ចឹមអន្ទង់ក្នុងអាងប្លាស្ទិចរយៈពេលបីឆ្នាំ ហើយទទួលបានជោគជ័យជាបន្តបន្ទាប់ មកចងក្រងជាឯកសារសម្រាប់ជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបន្ត និងជាត្រីវិស័យសម្រាប់កសិករ ដែលមានបំណងសាកល្បងចិញ្ចឹមអន្ទង់។

ឯកសារនេះ ត្រូវបានចងក្រងចែកជាពីរផ្នែក គឺផ្នែកសម្រង់បទពិសោធន៍តាមរយៈឯកសារដែលអ្នកស្រាវជ្រាវ បានចងក្រងកន្លងមក និងផ្នែកព័ត៌មាន ដែលប្រមូលបានពីកសិករដែលបានអនុវត្តផ្ទាល់។

យើងខ្ញុំ សូមការយោគយល់ អធ្យាស្រ័យអំពីកំហុសឆ្គង ការខ្វះចន្លោះទាំងឡាយ និងរងចាំទទួលយកនូវការរិះគន់កែលំអ ដើម្បីធ្វើឱ្យឯកសារនេះក្លាយជាឧបករណ៍ប្រកបដោយប្រសិទ្ធភាព ក្នុងការអភិវឌ្ឍន៍សកម្មភាពចិញ្ចឹមអន្ទង់កាន់តែផុលផុស។

យើងខ្ញុំ សូមសំដែងនូវគុណូបការៈដល់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ ក្នុងការដឹកនាំអភិវឌ្ឍឈានឡើងលើគ្រប់វិស័យ ក្នុងនោះបានគាំទ្រយ៉ាងពេញទំហឹងក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផល តាមរយៈការផ្តល់អនុសាសន៍ដ៏ឧត្តុង្គឧត្តម ដើម្បីជាត្រីវិស័យ។



សូមថ្លែងអំណរគុណអស់ពីដួងចិត្ត ដល់បេសកកម្មមិនខ្លាចនឿយហត់ ទាំងកម្លាំងកាយ និងកម្លាំងចិត្ត របស់ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលតែងតែដាស់តឿន ក្រើនរំលឹក ចង្អុលបង្ហាញ និងដាក់ចេញនូវយន្តការគ្រប់គ្រងប្រកបដោយថាមពល និងគតិបណ្ឌិត។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះឯកឧត្តម ណៅ ធួក ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល ដែលបានដឹកនាំអនុវត្តដោយផ្ទាល់ និងយ៉ាងសស្រាក់សស្រាំ ក្នុងនាមគ្រួសារតែមួយ ដើម្បីសម្រេចនូវអនុសាសន៍ដ៏ឧត្តុង្គឧត្តម របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា និងទស្សនៈវិស័យ របស់រដ្ឋបាលជលផល។

សូមប្រិយមិត្ត អ្នកអាន តាមដានស្វែងយល់ ពីបទពិសោធន៍នៃការចិញ្ចឹមអន្ទង់ ក្នុងអាងប្លាស្ទិក ដូចតទៅ:

## I-ផ្នែកឯកសារស្រាវជ្រាវ

ត្រីអន្ទង់ មានច្រើនប្រភេទណាស់។ អន្ទង់ស្រែ (Monoterus albus) ហើយអ្នកខ្លះហៅថាអន្ទង់តាម វាលភក់ ត្រូវបានគេចិញ្ចឹមតាមអាងស៊ីម៉ង់ ជាពិសេសនៅប្រទេសអាស៊ីនេះ។ លោក **ខឹម សារិទ្ធ** ប្រធានសហគមន៍ នេសាទរបាលស្នួង ដែលបានចិញ្ចឹមអន្ទង់ ក្នុងអាងប្លាស្ទិកទទួលបានជោគជ័យ រយៈពេល ៣ឆ្នាំកន្លងមក ហើយបានមានប្រសាសន៍ តាមភាសាសាមញ្ញថា អន្ទង់ មានបីប្រភេទ គឺអន្ទង់ត្រាវ អន្ទង់ដំណើប និងអន្ទង់ព្រ័ត។ អន្ទង់ ដែលអ្នកប្រើប្រាស់ចាត់ទុកថា មានរស់ជាតិជាងគេ គឺអន្ទង់ដំណើប ហើយអន្ទង់ដែលចាត់ទុកថាចិញ្ចឹមឆាប់ធំ គឺអន្ទង់ត្រាវ។

លក្ខណៈរូបរាងខាងក្រៅអន្ទង់ទាំងបីប្រភេទនេះ មានដូចខាងក្រោម :

១- អន្ទង់ត្រាវ : ក្បាលមានទំហំតូចជាងខ្លួន ផ្នែកពោះពណ៌ស លាយលឿងព្រឿងៗ និងមានអុចៗ

ពណ៌ខ្មៅ ផ្ទៃក្នុងមានពណ៌ត្នោត

២-អន្ទង់ដំណើប :ក្បាលមានទំហំធំជាងដងខ្លួន

៣-អន្ទង់ព្រ័ត : រូបរាងដូចជន្លេនដែក ពោះពណ៌ខ្មៅរាងស្វាយ

### ក. រូបភាពនៃការចិញ្ចឹម

ដោយសារកំណើននៃការតម្រូវការអន្ទង់ និងការស្វែងយល់ពីឱកាសរកផលចំណេញបានធ្វើឱ្យប្រជានេសាទ និង ប្រជាកសិករ ចាប់ផ្តើមទៅដល់ការប្រស់ ឬចិញ្ចឹម ប្រភេទអន្ទង់ ដើម្បីទុកលក់នៅរដូវ ដែលមានតម្លៃខ្ពស់។ តាមការ សិក្សាស្រាវជ្រាវនៅខេត្តបាត់ដំបង មានសកម្មភាពចិញ្ចឹមអន្ទង់តាមរូបភាព ពីរ គឺតាម ទ្រុង/បែ ឬត្រើង និងតាមអាង ប្លាស្ទិចតូចៗ។ ការចិញ្ចឹមតាម ទ្រុង/បែ ឬត្រើង ច្រើនអនុវត្តនៅភូមិសាស្រ្តតំបន់បឹងទន្លេសាប ជាពិសេសនៅ ឃុំព្រៃចាស់។ ចំណែកការចិញ្ចឹមក្នុងអាងតូចៗ សង្កេតឃើញមាននៅភូមិសាស្រ្តឃុំព្រែកនិរន្ទ និង ពាមឯក។ ការចិញ្ចឹម តាមរូបភាពទាំងពីរនេះ នៅមិនទាន់មានបច្ចេកទេសច្បាស់លាស់ សម្រាប់ការចិញ្ចឹមនៅឡើយទេ គឺគ្រាន់តែជាការ អនុវត្តតៗគ្នាប៉ុណ្ណោះ ហើយភាពជោគជ័យ និងបរាជ័យលាយឡំគ្នានៅឡើយ។

### ខ. ប្រភពកូនពូជអន្ទង់

ចំណុចមួយដែលគួរឱ្យសោកស្តាយគឺ កូនពូជអន្ទង់ ដែលបានយកមកចិញ្ចឹម គឺចាប់ពីធម្មជាតិទាំងស្រុង ដោយមិន ទាន់មានសមត្ថភាពភ្ញាស់នៅឡើយ។

### គ. ពេលវេលា ចិញ្ចឹម

ដោយសារកូនពូជ ត្រូវចាប់ពីធម្មជាតិ ដូច្នេះអ្នកចិញ្ចឹមទាំងឡាយ ត្រូវតែរង់ចាំរហូតដល់រដូវភ្លៀងធ្លាក់ ចាប់ពី ខែឧសភា ដល់ខែសីហា ទើបចាប់ផ្តើមរៀបចំទីតាំងដាក់កូនអន្ទង់ចិញ្ចឹម។ ពេលវេលា ដែលសំបូរកូនពូជអន្ទង់ជាងគេ គឺខែមេសា កក្កដា និងសីហា។

### ៣. ប្រភេទចំណីអន្ទង់

ចំណីអាហាររបស់អន្ទង់ គឺ ត្រីដែលមានតម្លៃថោក ខ្យង វារីសត្វ សត្វឥតឆ្អឹងកង ដង្កូវ ហើយគេអាចលាយផង ដែរ នឹងម្សៅត្រី ឬវីតាមីន។ ចំណីត្រូវលាយជាមួយសារធាតុស្អិត ដើម្បីជៀសវាងការខូចគុណភាពទឹកឆាប់រហ័សពេក។

### II. បទពិសោធន៍ នៃការចិញ្ចឹមអន្ទង់ តាមអាងប្លាស្ទិក របស់លោក ខឹម សារិទ្ធ

ក្រោយពីបានធ្វើការសាកល្បងអស់រយៈពេលពីរឆ្នាំ ក្នុងការចិញ្ចឹមអន្ទង់ក្នុងអាងប្លាស្ទិក លោក ខឹម សារិទ្ធ បានរកឃើញ វិធីសាស្រ្តដែលងាយ និងទទួលបានផលចំណេញច្រើនក្នុងឆ្នាំ២០០៩នេះ។ លោក ខឹម សារិទ្ធ បានបង្ហាញពីមោទនភាព និងមហិច្ឆតា ពង្រីកមុខរបរចិញ្ចឹមអន្ទង់ សម្រាប់នាពេលអនាគត និងបានផ្តល់បទពិសោធន៍ប្រកបដោយខ្លឹមសារ សម្រាប់យកមកចងក្រងឯកសារនេះ ដូចខាងក្រោម :

#### ១-ការរៀបចំអាង

#### ក- សម្ភារៈរួមផ្សំ

- បង្គោលឈើ របាឈើ បន្ទះព្រួល ថង់ប្លាស្ទិច(ថ្លា និងក្រាស់) ស្បៃនីឡុងក្រឡាញឹក ខ្សែនីឡុង ឬលួស ចំណង ដែកគោល និងទុយោជ័រ

- ទំហំ អាង សមរម្យ ៥ម គុណ ១,៥ម គុណ ០,៧ម

- វល្លិត្រកួន និងមែកសម្រាស់ (ដើមរាំង និងដើមត្រស់)

#### ខ- ការសាងសង់អាងប្លាស្ទិក

អាងចិញ្ចឹម ត្រូវសង់ពីលើដីផ្ទាល់តែម្តង ដែលការធ្វើបែបនេះ ងាយស្រួលក្នុងការបង្ហូរទឹកចេញ នៅពេលត្រូវការប្តូរទឹកថ្មី។ ទីតាំងត្រូវសាងសង់ គួរយកសំយាបផ្ទះ ចុងទរ ដែលអាចទទួលទឹកភ្លៀង បានច្រើន និងមិនទទួលរងកំដៅថ្ងៃ ខ្លាំងពេកផង។ បង្គោលឈើ ត្រូវដោតចូលទៅក្នុងដី ដែលមានចន្លោះពីមួយទៅមួយ ចំងាយ ០,៨ម ទៅ១ម រួចទើប ដាក់របា ផ្នែកខាងក្នុងអាង ដែលមានចន្លោះពីគ្នា ០,៣ម ទៅ០,៤ម។ បន្ទាប់មកចាប់ផ្តើមក្រាលព្រួលដាក់ត្រៀមបញ្ឈរ ចងរួចរាល់ រៀបស្បៃមុង រួចពាស់សំបត់កៅស៊ូតាមជញ្ជាំងព្រួល និងបាតក្រោមរួមគ្នាតែម្តង។ បំពង់បង្ហូរទឹកចេញ ត្រូវ ដាក់យ៉ាងតិច ពីរ នៅតាមជ្រុងនៃអាង។ ការរៀបចំសំបុក ជាជម្រក ដោយប្រើវល្លិត្រកួន ដែលបានហាលថ្ងៃឱ្យស្រពាប់ ពណ៌ក្រហមព្រឿងៗ(មួយអាទិត្យ) ហើយត្រាំទឹកឱ្យរលួយ ទើបយកមកដាក់ក្នុងអាង និងមែកសម្រាស់ មួយចំនួនដូចជា មែករាំង មែកត្រស់ (វល្លិត្រកួនត្រូវរៀបពីក្រោម ហើយដាក់មែកសម្រាស់ពីលើ ដើម្បីឱ្យអន្ទង់វារតោងស៊ីចំណី)។ ការចិញ្ចឹមនេះ មិនមានប្រើប្រាស់







ដីភក់ ឬដើមចេក ឬលាមកសត្វ ឬចំបើង ដូចមានសរសេរក្នុងឯកសារមួយចំនួននោះទេ។

ការបញ្ចូលទឹក ត្រូវមានកំពស់យ៉ាងតិច ០,៧ម ហើយត្រូវដាក់មុនពេលលែងកូនអន្ទង់ យ៉ាងតិច១០ថ្ងៃ ឬបញ្ចូល ទឹកចុះឡើង ធ្វើយ៉ាងណាឱ្យទឹកបាត់ក្លិនស្អុយ ពីវល្លិ៍ត្អើក និងមែកសម្រាស់សិន។ កំប្លោក ឬចក មិនមែនជាកត្តាចាំបាច់ត្រូវតែដាក់នោះទេ។

**២-ការលែងកូនអន្ទង់ពូជ**

ក-ការជ្រើសរើសកូនអន្ទង់ពូជ



មិនខុសពីត្រីនោះទេ ការលែងកូនពូជ ទំហំខុសគ្នាធ្វើឱ្យមានការប្រជែងគ្នាស៊ីចំណី បណ្តាលឱ្យការធំធាត់ក៏ខុសគ្នាដែរ។ យើងត្រូវគិតផងដែរថា អន្ទង់ ជាប្រភេទសត្វស៊ីសាច់ជាអាហារ ដូច្នេះ នៅពេលខ្វះចំណី អន្ទង់ធំ អាចស៊ីអន្ទង់ តូចបាន។ កូនអន្ទង់ត្រូវលែង ត្រូវមានទំហំខុសគ្នាតិចបំផុត។ ទំហំកូនអន្ទង់ពូជ យកមកចិញ្ចឹម ត្រូវមានចំនួន ២០ក្បាល ក្នុងមួយគីឡូក្រាម យ៉ាងច្រើន គឺផ្តល់អត្រារស់ខ្ពស់។

ខ-ប្រភេទអន្ទង់

ប្រភេទអន្ទង់ ក៏ត្រូវគិតដែរ ដោយផ្តោតទៅលើតម្រូវការទីផ្សារ និងកំរិតលូតលាស់ ធំធាត់។ ប្រភេទអន្ទង់ដែលសមស្របបំផុត គឺអន្ទង់ដំណើប និងអន្ទង់ត្រាវ។

**គ-ដង់ស៊ីតេចិញ្ចឹម**

តាមបទពិសោធន៍កន្លងមកកូនអន្ទង់ដែលមានទម្ងន់ ២០ក្បាល ក្នុងមួយគីឡូក្រាម ដាក់ចិញ្ចឹម ក្នុងដង់ស៊ីតេ២០០ក្បាល ទៅ២៥០ក្បាល ក្នុងមួយម៉ែត្រការ៉េ។

**ឃ-ការដឹកជញ្ជូន និងពេលវេលាលែងកូនអន្ទង់**

មតិភាគច្រើនយល់ថាអន្ទង់ជាប្រភេទសត្វមានភាពធន់ទ្រាំនឹងបរិយាកាស និងអុកស៊ីសែនទាប តែងមិនបានគិតដល់ការរក្សាគុណភាពកូនអន្ទង់ត្រូវដាក់ចិញ្ចឹមហើយតែងធ្វើការដឹកជញ្ជូនមិនបានត្រឹមត្រូវ។ មិនខុសពីត្រីទេ កាលណាដឹកជញ្ជូនមិនបានសមស្របធ្វើឱ្យកូនអន្ទង់បាក់កម្លាំង របួសខ្លួន អាចងាប់ក្រោយពេលដាក់ចូលអាង ឬ កម្រ ចាប់ចំណី ឬធ្វើឱ្យក្រិន ធំធាត់យឺត។ ដូច្នេះ ការដឹកជញ្ជូនអន្ទង់ ទោះបីមិនមានអុកស៊ីសែន យើងត្រូវដាក់វាក្នុងបរិមាណ មួយសមស្របដែរ។ ពេលវេលាដាក់ចូលអាង គួរកំណត់យកពេលរសៀល គឺល្អ។ ការលែង ត្រូវអនុវត្តដោយការបាចទឹក បញ្ចូលបន្តិចម្តងៗ ដើម្បីមានលក្ខណៈបន្សាំទៅមជ្ឈដ្ឋានថ្មីបានល្អដែរ។

**៣-ការផ្តល់ចំណី**

ក-ប្រភេទចំណី

ប្រភេទចំណីដែលបានផ្តល់ឱ្យអន្ទង់ស៊ី រួមមាន ត្រីដែលគុណភាពទាប ខ្យង ដែលចាប់ពីតាមវាលស្រែ បឹង...និង កន្ធក់ទៅតាមដំណាក់កាលនីមួយៗ។

នៅខែទីមួយ ប្រភេទចំណីអន្ទង់ ប្រើប្រភេទត្រីគុណភាពទាប ស្រុះជាមួយទឹកក្តៅ លាយជាមួយខ្យងចិញ្ច្រាំ ហើយចាប់ពីខែទីពីរទៅ ប្រភេទចំណីអន្ទង់ ប្រើត្រីគុណភាពទាប ស្រុះជាមួយទឹកក្តៅ លាយជាមួយខ្យងចិញ្ច្រាំ និង កន្ធក់។ សមាសធាតុត្រីក្នុងចំណី មិនអាចខ្វះបានទេ តែខ្យង និងកន្ធក់ អាចខ្វះបាន។ ប៉ុន្តែការលាយចូលគ្នារវាងត្រី និង កន្ធក់ ត្រូវបានប្រើទឹក



ញាប់ ព្រោះងាយរក កាត់បន្ថយប្រាក់ចំណាយ និងអាចរក្សាប្រាក់ចំណេញបាន។

**ខ-ពេលវេលាផ្តល់ចំណី**

ពេលល្ងាច ជាពេលវេលាល្អ សម្រាប់ការផ្តល់ចំណី។ នៅពេលទឹកក្នុងអាងឡើងស្អុយ អន្ទង់មិនស៊ីចំណីទេ។ នៅពេលប្តូរទឹកភ្លាមៗក្រោយរយៈពេលបីថ្ងៃទើបអន្ទង់ចាប់ស៊ីចំណី ព្រោះនៅពេលប្តូរទឹកភ្លាមអន្ទង់មិនស៊ីចំណីទេ។

**គ-របៀបផ្តល់ចំណី**

យើងមិនត្រូវដាក់ចំណីអន្ទង់ ដោយបោះចូលទៅក្នុងទឹកផ្ទាល់ទេ យើងត្រូវរៀបចំឱ្យមានកញ្ច្រែង ព្យួរប៉ប្រ៉ះផ្ទៃ ទឹក។ នៅពេលផ្តល់ចំណី យើងគ្រាន់តែដាក់ចំណីនៅលើកញ្ច្រែង ជាការស្រេច។ ចំពោះទំហំអាងរៀបរាប់ខាងលើ គួរដាក់ កញ្ច្រែងឱ្យបានយ៉ាងតិចបីកន្លែងផ្សេងៗគ្នា។

**ឃ-បរិមាណចំណី**

មិនទាន់មានការគណនាច្បាស់លាស់នៅឡើយ អំពីបរិមាណចំណីដែលបានផ្តល់ម្តងៗ។ ប៉ុន្តែតាមការអះអាង ក្នុងរយៈពេលចិញ្ចឹម ៨ខែ ទម្ងន់ពូជ ៥០គ.ក្រ ប្រើវត្ថុធាតុដើមចំណីរួមមាន កន្ទក់ ១២,៥គ.ក្រ និងត្រីគុណភាពទាបចំនួន ៥០គ.ក្រ។ រយៈពេលបីថ្ងៃ ទើបឱ្យចំណីស៊ីម្តង។

**៤-ការតាមដានគុណភាពទឹក និងការផ្លាស់ប្តូរទឹក**

ការតាមដានផ្លាស់ប្តូរទឹកមានលក្ខណៈងាយដឹង តាមរយៈការអន់ស៊ីចំណី។ ទឹកស្អុយពេក អន្ទង់មិនស៊ីចំណីទេ។ ដូច្នេះ ជាសញ្ញាបង្ហាញឱ្យយើងត្រូវធ្វើការផ្លាស់ប្តូរទឹក។ បើមិនដូច្នោះទេ នៅរាល់១៥ថ្ងៃម្តង យើងត្រូវតែធ្វើការផ្លាស់ប្តូរ ទឹក ដោយបង្ហូរតាមបំពង់ដែលរៀបចំរួចជាស្រេច។

**៥-ជំងឺអន្ទង់**

អន្ទង់ចិញ្ចឹម នៅអំឡុងខែមករា កុម្ភៈ មីនា ភាគច្រើនសង្កេតឃើញមានដំបៅ តែក៏មិនទាន់មានការសន្និដ្ឋានថា បណ្តាលមកពីមានជំងឺ ឬ ការប៉ះទង្គិចគ្នា ឬ ខាំគ្នា។ ការព្យាបាល គឺប្រើដើមត្រស់ កាត់ជាកង់ៗ ត្រាំទៅក្នុងទឹក ដើម្បីឱ្យ ចេញជ័រខ្មៅៗ រយៈពេល ១៥-២០ថ្ងៃ នឹងឃើញថាជាសះស្បើយវិញ។

**៦-ការប្រមូលផល**

ដូចរៀបរាប់ខាងលើ រយៈពេលចិញ្ចឹមអន្ទង់ មាន ៨ ខែ។ ដោយពូជអន្ទង់ប្រមូលពីធម្មជាតិ ហើយស្ថិតក្នុង ដំណាក់កាល ពូជអន្ទង់សំបូរ និងថោកនោះ ការប្រមូលផលអន្ទង់ ភាគច្រើនស្ថិតក្នុងខែមករា ឬកុម្ភៈ ឬ មីនា។ ក្នុងចន្លោះ ពេលពីខែមករា ដល់ខែមីនា ជារដូវប្រាំង អន្ទង់ត្រូវការរស់នៅក្រាំង ក្នុងដី ធ្វើឱ្យលំបាកក្នុងការនេសាទ ដូច្នេះតម្លៃ ក្នុងចន្លោះពេលនេះក៏មានតម្លៃខ្ពស់ជាងគេ ក្នុងឆ្នាំ។





